# **គំរូដ៏ល្អឥតខ្ចោះរបស់យើង**

ប្រធាន ហិនរី ប៊ី អាវរិង
ទីប្រឹក្សាទីមួយនៅក្នុងគណៈប្រធានទីមួយ

*សារលិខិតនៃដំណឹងល្អដែលបានស្តារឡើងវិញរបស់ព្រះយេស៊ូវ គឺដើម្បីឱ្យយើងអាច ហើយត្រូវតែរំពឹងទុកថា នឹងប្រែក្លាយទៅជាមនុស្សកាន់តែល្អ ដរាបណាយើងនៅមានជីវិត ។*

ខ្ញុំទទួលអារម្មណ៍ពរជ័យណាស់ ដើម្បីមានឱកាសនិយាយទៅកាន់អ្នករាល់គ្នាក្នុងថ្ងៃបរិសុទ្ធនេះ ។ ទោះបីជាយើងមានស្ថានភាព និងបទពិសោធន៍ខុស១គ្នា ក៏យើងចែកចាយនូវបំណងប្រាថ្នាមួយ ដើម្បីប្រែក្លាយជាមនុស្សកាន់តែល្អដែរ ។ មានមនុស្សមួយចំនួនតូចយល់ខុសថាពួកគេល្អគ្រប់គ្រាន់ហើយ ហើយមានមួយចំនួនតូចទៀតបានបោះបង់ការព្យាយាមដើម្បីប្រែក្លាយជាមនុស្សកាន់តែល្អ ។ ប៉ុន្តែចំពោះមនុស្សគ្រប់រូប សារលិខិតនៃដំណឹងល្អនៃព្រះយេស៊ូវដែលបានស្តារឡើងវិញ គឺដើម្បីឱ្យយើងអាច ហើយត្រូវតែរំពឹងទុកថា នឹងប្រែក្លាយទៅជាមនុស្សកាន់តែល្អ ដរាបណាយើងនៅមានជីវិត ។

ចំណែកនៃការរំពឹងទុកនោះ គឺបានរៀបចំសំរាប់យើងនៅក្នុងវិវរណៈមួយ ដែលព្រះបានប្រទានឱ្យព្យាការីយ៉ូសែប ស្ម៊ីធ ។ វាមានការពិពណ៌នាអំពីថ្ងៃដែលយើងនឹងជួបព្រះអង្គសង្គ្រោះ ដែលយើងទាំងអស់គ្នានឹងជួប ។ វិវរណៈប្រាប់យើងនូវអ្វីដែលយើងត្រូវធ្វើដើម្បីរៀបចំខ្លួន និងអ្វីដែលរំពឹងទុក ។

វាមាននៅក្នុងគម្ពីរមរ៉ូណៃ: "ហេតុដូច្នោះហើយ ឱបងប្អូនដ៏ជាទីស្រឡាញ់របស់ខ្ញុំអើយ ចូរអធិស្ឋានដល់ព្រះវរបិតាដោយអស់ពីកម្លាំងចិត្តដើម្បីឱ្យអ្នករាល់គ្នាបានពោរពេញដោយសេចក្តីស្រឡាញ់នេះ ដែលទ្រង់បានប្រទានដល់អ្នកណាដែលជាអ្នកដើរតាមដ៏ពិតនៃព្រះរាជបុត្រារបស់ទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ ដើម្បីឱ្យអ្នករាល់គ្នាអាចក្លាយទៅជាកូនព្រះ ដើម្បីកាលណាទ្រង់នឹងលេចមក នោះយើងរាល់គ្នានឹងបានដូចជាទ្រង់ ត្បិតយើងនឹងឃើញទ្រង់ ជាទ្រង់ពិតប្រាកដ ដើម្បីឱ្យយើងអាចមានសេចក្តីសង្ឃឹមនេះ ដើម្បីឱ្យយើងអាចបានបរិសុទ្ធដូចជាទ្រង់បរិសុទ្ធ ។ អាម៉ែន" ។ 1

រឿងនោះគួរតែជួយដល់អ្នកឱ្យយល់ថាហេតុអ្វីក៏ពួកបរិសុទ្ធថ្ងៃចុងក្រោយគ្រប់រូប មានសុទិដ្ឋិនិយមមួយអំពីអ្វីដែលមាននៅខាងមុខសំរាប់គាត់ ឬនាង ទោះជាវាមានការលំបាកយ៉ាងណាក៏ដោយ ។ យើងជឿថា តាមរយៈការរស់នៅតាមដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ យើងអាចប្រែក្លាយដូចជាព្រះអង្គសង្គ្រោះ ដែលល្អឥតខ្ចោះ ។ មនុស្សឆ្មើងឆ្មៃដែលបំពេញចិត្តតែខ្លួនឯង ហើយគិតថាគាត់ ឬនាងមិនត្រូវការកែលំអរ គួរតែត្រូវបានបង្រាប នៅពេលពួកគេពិចារណាអំពីលក្ខណៈរបស់ព្រះយេស៊ូវគ្រីស្ទ ។ ហើយសូម្បីតែមនុស្សដែល រាបទាបបំផុត ក៏អាចមានសេចក្តីសង្ឃឹមនៅក្នុងការអញ្ជើញឱ្យកាន់តែប្រែក្លាយ ដូចជាព្រះអង្គសង្គ្រោះដែរ ។

សំរាប់យោបល់របស់ខ្ញុំ ចំរៀងដែលនិពន្ធឡើងសំរាប់កុមារតូច១ គឺបានបង្ហាញយ៉ាងអស្ចារ្យអំពីការផ្លាស់ប្តូរ ដែលនឹងកើតឡើង ។ នៅថ្ងៃអាទិត្យមួយ ខ្ញុំចាំថាខ្ញុំបានទៅបន្ទប់មួយដែលមានសុទ្ធតែកុមារតូច១ មើលទៅមុខរបស់ពួកគេ ។ កុមារម្នាក់១ទ្រោបខ្លួនទៅខាងមុខ ស្ទើរតែអង្គុយនៅគែមកៅអី ។ ខ្ញុំអាចមើលឃើញពន្លឺ នៅក្នុងកែវភ្នែករបស់ពួកគេ និងការប្តេជ្ញាចិត្តនៅលើមុខរបស់

ពួកគេ នៅពេលពួកគេច្រៀងដោយរីករាយចេញពីចិត្ត។ អ្នកប្រហែលជាធ្លាប់ឮចំរៀងនេះផងដែរ។ ខ្ញុំសង្ឃឹមថាវានឹងឮជារៀងរហូត នៅក្នុងការចងចាំរបស់យើង។ ខ្ញុំគ្រាន់តែសង្ឃឹមថា ខ្ញុំអាចផ្តល់ឱ្យនូវអារម្មណ៍ដែលកុមារគ្រប់រូបមាន។

*ខ្ញុំ* ខំក្លាយដូចជាព្រះយេស៊ូវ *ខ្ញុំ* ធ្វើតាមគំរូនៃទ្រង់។
*ខ្ញុំ* ខំស្រឡាញ់ដូចព្រះអង្គនូវអ្វីគ្រប់អ្វីដែលខ្ញុំធ្វើ និងថា។
ជួនកាលខ្ញុំបានល្បួង រើសអ្វីដែលមិនត្រូវ
តែខ្ញុំខំស្តាប់ឮពីសំឡេងតូចរហៀងខ្សឹបប្រាប់ខ្ញុំ
"*ស្រឡាញ់* អ្នកដទៃដូចព្រះស្រឡាញ់អ្នក។
ខំបង្ហាញចិត្តស្រឡាញ់ អ្វីដែលអ្នកធ្វើមានចិត្តស្លូត ស្រឡាញ់គ្រប់កិច្ចការ និងគំនិត
នេះជាអ្វីដែលទ្រង់បាន*បង្រៀន*" ។2

ចំពោះខ្ញុំវាហាក់ដូចជាពួកគេមិនគ្រាន់តែច្រៀងប៉ុណ្ណោះនោះទេ តែពួកគេកំពុងប្រកាសពីការប្តេជ្ញាចិត្តរបស់ខ្លួន។ ព្រះយេស៊ូវគ្រីស្ទគឺជាគំរូរបស់ពួកគេ។ ដើម្បីប្រែក្លាយដូចជាទ្រង់ គឺជាគោលដៅដ៏មុតមាំរបស់ពួកគេ។ ហើយការមើលដោយ មានបំណងប្រាថ្នា និងកែវភ្នែកចែងចាំងរបស់ពួកគេធ្វើឱ្យខ្ញុំជឿថា ពួកគេគ្មានសង្ស័យទេ។ ពួកគេរំពឹងទុកថាជោគជ័យ។ ពួកគេ ជឿលើការបង្រៀនរបស់ព្រះអង្គសង្គ្រោះដើម្បីបានល្អឥតខ្ចោះ មិនមែនជាសេចក្តីសង្ឃឹមមួយទេ ប៉ុន្តែជាបញ្ជាមួយ។ ហើយពួកគេដឹងប្រាកដថាទ្រង់បានរៀបចំផ្លូវ។

ការប្តេជ្ញាចិត្ត និងទំនុកចិត្តនោះ អាច និងត្រូវតែមាននៅក្នុងដួងចិត្តរបស់ពួកបរិសុទ្ធថ្ងៃចុងក្រោយគ្រប់រូប។ ព្រះអង្គសង្គ្រោះបានរៀបចំផ្លូវតាមរយៈដង្វាយធួន និងគំរូរបស់ទ្រង់។ ហើយសូម្បីតែកុមារតូចៗដែលច្រៀងបទនោះ បានដឹងរបៀបដើម្បីក្លាយដូចជាទ្រង់។

សេចក្តីស្រឡាញ់ គឺជាគោលការណ៍ជំរុញទឹកចិត្តដែលព្រះអម្ចាស់ដឹកនាំយើងនៅតាមផ្លូវឆ្ពោះទៅរកការប្រែក្លាយដូចជា ទ្រង់ *ជាគំរូដ៏ល្អឥតខ្ចោះរបស់យើង* ។ នៅគ្រប់នាទីនៃវិថីជីវិតរបស់យើង ត្រូវតែបំពេញដោយសេចក្តីស្រឡាញ់ចំពោះព្រះ និងចំពោះអ្នកដទៃ។ គ្មានការភ្ញាក់ផ្អើលអំពីរឿងនោះទេ ចាប់តាំងពីព្រះអម្ចាស់បានប្រកាសរឿងនោះថាជាបទបញ្ញត្តិទីមួយ និងធំបំផុត។ វាគឺជាការស្រឡាញ់ចំពោះព្រះ ដែលនឹងដឹកនាំយើងឱ្យគោរពព្រះបញ្ញត្តិរបស់ទ្រង់។ ហើយស្រឡាញ់ចំពោះអ្នកដទៃ គឺស្ថិតនៅចំណុចសំខាន់នៃសមត្ថភាពរបស់យើងដើម្បីគោរពទ្រង់។

ដូចជាព្រះយេស៊ូវបានប្រើប្រាស់កុមារតូចម្នាក់នៅក្នុងការបំរើនៅជីវិតរមែងស្លាប់របស់ទ្រង់ ធ្វើជាគំរូមួយសំរាប់មនុស្សអំពីសេចក្តីស្រឡាញ់សុទ្ធសាធ ដែលពួកគេត្រូវតែ ហើយអាចមានដើម្បីប្រែក្លាយដូចជាទ្រង់ ទ្រង់បានប្រទានគ្រួសារដល់យើងជាគំរូដ៏វិសេសមួយ ដែលយើងអាចរៀនស្រឡាញ់ដូចជាទ្រង់ស្រឡាញ់។

នោះគឺដោយសារតែសេចក្តីអំណរដ៏មហិមាបំផុត និងសោកសៅបំផុត ដែលយើងមានបទពិសោធន៍ នៅក្នុងទំនាក់ទំនងគ្រួសារ។ សេចក្តីអំណរកើតមានពីការដាក់សុខុមាលភាពរបស់អ្នកដទៃខ្ពស់ជាងខ្លួនយើង។ នោះគឺជាសេចក្តីស្រឡាញ់។ ហើយ ភាពសោកកាកើតមានជាសំខាន់មកពីភាពអត្មានិយម ដែលអវត្តមានសេចក្តីស្រឡាញ់។ គំរូមួយដែលព្រះមានបំណងព្រះទ័យសំរាប់យើង គឺឱ្យបង្កើតក្រុមគ្រួសារតាមរបៀបមួយដែលនាំទៅរកសុភមង្គល និងចៀសចេញពីភាពសោកសៅ។ បុរស និងស្ត្រី ត្រូវធ្វើសេចក្តីសញ្ញាពិសិដ្ឋ ដែលពួកគេនឹងដាក់សុខុមាលភាព និងសុភមង្គលរបស់គ្នាទៅវិញទៅមកជាសំខាន់ នៅក្នុងជីវិតរស់នៅរបស់ពួកគេ។ កុមារតូចៗត្រូវកើតមកនៅក្នុងគ្រួសារមួយ ដែលឪពុកម្តាយគោរពតាមសេចក្តីត្រូវការ របស់កូនម្នាក់ៗស្មើគ្នាទៅនឹងសេចក្តីត្រូវការសំខាន់ផ្ទាល់ខ្លួនរបស់ពួកគេ។ ហើយកូនៗគឺត្រូវស្រឡាញ់ឪពុកម្តាយ និងស្រឡាញ់គ្នាទៅវិញទៅមក។

នោះគឺជាគំរូនៃគ្រួសារជាទីស្រឡាញ់មួយ។ នៅក្នុងគេហដ្ឋានរបស់យើងរាល់គ្នាជាច្រើន មានពាក្យថា: "ក្រុមគ្រួសារអាចរស់នៅជាមួយគ្នាជានិរន្តរ៍"។ មានផ្ទាំងក្បាលផ្ទះមួយនៅជិតផ្ទះរបស់ខ្ញុំ ជារបស់ស្ត្រីម្នាក់។ គាត់ និងស្វាមីរបស់គាត់បានផ្សារភ្ជាប់ជាមួយគ្នា និងជាមួយកូនចៅរបស់ពួកគាត់ នៅក្នុងព្រះវិហារបរិសុទ្ធរបស់ព្រះ សំរាប់ជីវិតនេះ និងជីវិតអស់កល្បជានិច្ច។ ការចារិកនៅលើផ្ទាំងផ្ទះសរសេរថា "សូមកុំឱ្យមានកៅអីទំនេរ"។ គាត់បានសុំឱ្យចារិកពាក្យដូច្នោះ ដោយសារតែគាត់ដឹងថា ក្រុមគ្រួសារនឹងនៅជាមួយគ្នា អាស្រ័យទៅលើការជ្រើសរើស ដែលសមាជិកក្រុមគ្រួសារម្នាក់ៗបានធ្វើ។ ពាក្យ "សូម" គឺមាននៅទីនោះ ដោយសារតែថា ព្រះ ឬគាត់ មិនអាចបង្ខំនរណាម្នាក់ឱ្យជ្រើសរើសសុភមង្គលនោះទេ។ ហើយមានសាតាំងដែលចង់ឱ្យក្រុមគ្រួសារមានទុក្ខវេទនា និងគ្មានសុភមង្គលនៅក្នុងជីវិតនេះ និងនៅជីវិតបន្ទាប់។

សេចក្តីសង្ឃឹមរបស់ខ្ញុំនៅថ្ងៃនេះគឺ ចង់ផ្តល់យោបល់អំពីការជ្រើសរើសមួយចំនួន ដែលមើលទៅហាក់ដូចជាលំបាក តែវានឹងអះអាងដល់អ្នកថា អ្នកមានគុណសម្បត្តិដើម្បីកុំមានកៅអីទំនេរនៅក្នុងគ្រួសាររបស់អ្នក នៅពិភពខាងមុខ។

ទីមួយ ខ្ញុំសូមផ្តល់ដំបូន្មានទៅដល់ស្វាមី និងភរិយា។ សូមអធិស្ឋានសុំសេចក្តីស្រឡាញ់ ដែលនាំឱ្យអ្នកមើលឃើញសេចក្តីល្អដៃគូរបស់អ្នក។ សូមអធិស្ឋានសុំសេចក្តីស្រឡាញ់ ដែលធ្វើឱ្យភាពទន់ខ្សោយ និងកំហុសជារឿងតូចតាច។ សូមអធិស្ឋានសុំសេចក្តីស្រឡាញ់ ដើម្បីធ្វើឱ្យអ្នកមានសេចក្តីអំណរដូចដៃគូរបស់អ្នក។ សូមអធិស្ឋានសុំសេចក្តីស្រឡាញ់ ដើម្បីចង់សម្រាលបន្ទុក ហើយរសាយភាពសោកសៅរបស់ដៃគូអ្នក។

ខ្ញុំបានមើលឃើញរឿងនេះនៅក្នុងអាពាហ៍ពិពាហ៍របស់ឪពុកម្តាយខ្ញុំ។ នៅពេលម្តាយខ្ញុំមានជំងឺធ្ងន់ធ្ងរខ្លាំង ពេលម្តាយខ្ញុំកាន់តែមិនស្រួល នោះជីវិតឪពុករបស់ខ្ញុំកាន់តែផ្តោតលើការផ្តល់ការលួងលោមដល់គាត់។ ឪពុកខ្ញុំបានសុំឱ្យមន្ទីរពេទ្យរៀបចំគ្រែនៅក្នុងបន្ទប់របស់ម្តាយខ្ញុំ។ គាត់ប្តេជ្ញាចិត្តដើម្បីនៅទីនោះមើលឱ្យប្រាកដថា ម្តាយរបស់ខ្ញុំទទួលបាននូវអ្វីៗដែលគាត់ត្រូវការ។ ឪពុកខ្ញុំបានដើររាប់គីឡូម៉ែត្រដើម្បីធ្វើការរាល់ព្រឹក ហើយត្រឡប់មកវិញនៅជិតប្រពន្ធនាពេលយប់ គ្រប់គ្រាដែលប្រពន្ធមានការលំបាក។ ខ្ញុំជឿថាវាគឺជាអំណោយទានមួយ មកពីព្រះសំរាប់គាត់ ដើម្បីឱ្យអំណាចនៃសេចក្តីស្រឡាញ់របស់គាត់បានរីកចំរើន នៅពេលដែលវាមានសារៈសំខាន់បំផុតសំរាប់ម្តាយខ្ញុំ។ ខ្ញុំគិតថា គាត់កំពុងតែធ្វើនូវអ្វីដែលព្រះយេស៊ូវនឹងធ្វើ ដោយសារសេចក្តីស្រឡាញ់។

ឥឡូវនេះ ខ្ញុំសូមផ្តល់ដំបូន្មានដល់ឪពុកម្តាយ ដែលមានកូនមិនរស់នៅតាមដំណឹងល្អថា: ព្រះអង្គសង្គ្រោះ គឺជាគំរូដ៏ល្អឥតខ្ចោះនៃភាពខ្ជាប់ខ្ជួននៅក្នុងសេចក្តីស្រឡាញ់។ អ្នកមាននៅចងចាំព្រះបន្ទូលរបស់ទ្រង់ ដែលលួងលោមដល់ប្រជាជននៅក្នុងចំណោមពួកសាសន៍នីហ្វៃ ដែលបានបដិសេធការអញ្ជើញកាលពីមុនរបស់ទ្រង់ ថាឱ្យមករកទ្រង់នោះទេ។ ទ្រង់បានមានបន្ទូលទៅកាន់អ្នកដែលនៅរស់ពីការបំផ្លិចបំផ្លាញ ដែលកើតមានបន្ទាប់ពីការឆ្កាងរបស់ទ្រង់ថា: "ឱអ្នករាល់គ្នាដែលជាវង្សអ៊ីស្រាអែល ជាអ្នកដែលយើងបានលើកលែងអើយ ជាញឹកញាប់យ៉ាងណាទៅ ដែលយើងបានប្រមូលអ្នករាល់គ្នា ដូចជាមេមាន់ប្រមូលកូនរបស់វានៅក្រោមស្លាបវា បើសិនជាអ្នករាល់គ្នាព្រមប្រែចិត្ត ហើយត្រឡប់មករកយើង ដោយអស់ពីដួងចិត្ត"។3

រឿងអំពីកូនប្រុសខ្ជះខ្ជាយ ផ្តល់សេចក្តីសង្ឃឹមដល់យើងទាំងអស់គ្នា។ កូនប្រុសខ្ជះខ្ជាយបាននឹកចាំអំពីផ្ទះ ដូចគ្នានឹងកូនៗរបស់អ្នកផងដែរ។ ពួកគេនឹងទទួលអារម្មណ៍សេចក្តីស្រឡាញ់របស់អ្នក ទាញពួកគេឱ្យត្រឡប់មករកអ្នកវិញ។ អែលឌើរ អ័សុន អែហ្វ វីតនី នៅក្នុងសន្និសីទទូទៅឆ្នាំ 1929 មួយ បានផ្តល់ការសន្យាដ៏អស្ចារ្យ ដែលខ្ញុំដឹងថាគឺជាការពិតចំពោះឪពុកម្តាយស្មោះត្រង់ ដែលគោរពដល់ការផ្សាភ្ជាប់ ក្នុងព្រះវិហារបរិសុទ្ធ ចំពោះកូនៗរបស់ពួកគេ: "ត្បិតមានកូនចៀមខ្លះប្រហែលជាវង្វេង តែភ្នែករបស់អ្នកគង្វាលមើល ទៅលើពួកគេ ហើយមិនយូរមិនឆាប់ ពួកគេនឹងទទួលអារម្មណ៍នៃការឈោងទៅពាល់ដោយទិព្វញាណនៃព្រះតាមពួកគេ ហើយទាញពួកគេត្រឡប់មកក្នុងហ្វូងវិញ"។

បន្ទាប់មកគាត់បន្តទៀតថា : "ចូរអធិស្ឋានឱ្យកូនដែលមិនយកចិត្តទុកដាក់ និងមិនគោរពប្រតិបត្តិរបស់អ្នក តោងជាប់ពួកគេដោយសេចក្តីជំនឿរបស់អ្នក។ បន្តមានសង្ឃឹម បន្តមានការទុកចិត្ត រហូតដល់អ្នកមើលឃើញសេចក្តីសង្គ្រោះរបស់ព្រះ"។4 អ្នកអាចអធិស្ឋានសំរាប់កូនៗរបស់អ្នក ស្រឡាញ់ពួកគេ ហើយឈោងទៅរកពួកគេដោយមានទំនុកចិត្តថា ព្រះយេស៊ូវលូកព្រះហស្តទៅរកពួកគេជាមួយនឹងអ្នក។ នៅពេលអ្នកបន្តព្យាយាម នោះអ្នកកំពុងតែធ្វើអ្វីដែលព្រះយេស៊ូវធ្វើ។

ឥឡូវនេះ គឺជាដំបូន្មានរបស់ខ្ញុំចំពោះកូនៗ។ ព្រះអម្ចាស់ប្រទានបញ្ញត្តិមួយដល់អ្នក ព្រមជាមួយនឹងការសន្យាមួយថា: "ចូរឱ្យគោរពប្រតិបត្តិដល់ឪពុកម្តាយ ដើម្បីឱ្យបានអាយុវែងនៅក្នុងស្រុក ដែលព្រះយេស៊ូវគ្រីស្ទ ជាព្រះនៃឯងទ្រង់ប្រទានឱ្យ"។5 វាគឺជាបទបញ្ញត្តិតែមួយគត់នៅក្នុងក្រិត្យវិន័យដប់ប្រការ ដែលមាននូវការសន្យា។ អ្នកប្រហែលជាគ្មានឪពុកម្តាយដែលនៅរស់ទេ។ ក្នុងករណីមួយចំនួន អ្នកប្រហែលជាមានអារម្មណ៍ថា ឪពុកម្តាយរបស់អ្នកមិនសក្តិសមនឹងឱ្យកូនៗរបស់ពួកគាត់គោរពកោតសរសើរទេ។ អ្នកប្រហែលជាមានអារម្មណ៍ថាមិនស្គាល់ពួកគាត់ទេ។ ប៉ុន្តែអ្នកជំពាក់ជីវិតពួកគាត់។ ហើយនៅគ្រប់ករណី សូម្បីតែជីវិតរបស់អ្នកមិនបានយូរអង្វែង ជាធម្មតាវានឹងកែលំអរ នៅពេលចងចាំឪពុកម្តាយរបស់អ្នកដោយការគោរព។

ឥឡូវ ចំពោះអ្នកទាំងឡាយដែលបានសុំគ្រួសាររបស់អ្នកដទៃមកធ្វើជាគ្រួសាររបស់ខ្លួន: ខ្ញុំមានមិត្តភក្តិជាច្រើន ដែលចងចាំអំពីថ្ងៃខួបកំណើតកូនៗរបស់ខ្ញុំជាងរូបខ្ញុំ។ ភរិយារបស់ខ្ញុំ និង ខ្ញុំ មានមិត្តភក្តិជាច្រើន ដែលកម្រថា មិនបានមកលេង ឬចងចាំថ្ងៃឈប់សំរាកជាមួយយើងណាស់។ ជារឿយៗខ្ញុំត្រូវបានទទួលការប៉ះនឹងដួងចិត្ត នៅពេលនរណាម្នាក់ចាប់ផ្តើមការសន្ទនាមួយដោយនិយាយថា "តើក្រុមគ្រួសាររបស់អ្នកសុខសប្បាយឬទេ?" ហើយក្រោយមករង់ចាំស្តាប់ចម្លើយដោយក្តីស្រឡាញ់ បង្ហាញនៅលើទឹកមុខរបស់ពួកគេ។ ពួកគេហាក់ដូចជាយកចិត្តទុក ដាក់ណាស់ នៅពេលខ្ញុំពិពណ៌នាអំពីជីវិតកូនរបស់ខ្ញុំម្នាក់ៗ។ សេចក្តីស្រឡាញ់

របស់ពួកគេបានជួយខ្ញុំទទួលអារម្មណ៍ កាន់តែចង់បានសេចក្ដីស្រឡាញ់នៃព្រះអង្គសង្គ្រោះខ្លាំងឡើងសំរាប់កូនៗរបស់យើង។ នៅក្នុងសំណួររបស់ពួកគេ ខ្ញុំអាចយល់ថា ពួកគេកំពុងមានអារម្មណ៍នូវអ្វីដែលព្រះយេស៊ូវមានព្រះទ័យ និងកំពុងតែសួរនូវអ្វីដែលទ្រង់នឹងសួរ។

ត្បិតយើងទាំងអស់គ្នា អាចមានការលំបាកដើម្បីមើលឃើញនៅក្នុងជីវិតរស់នៅរបស់យើងនូវអំណាចដើម្បីស្រឡាញ់ និងការមើលឃើញខ្លួនឯងប្រែក្លាយដូចជាព្រះអង្គសង្គ្រោះ *ជាគំរូដ៏ល្អឥតខ្ចោះរបស់យើង* ណាស់។ ខ្ញុំចង់លើកទឹកចិត្ត អ្នករាល់គ្នា។ អ្នកមានភស្តុតាងថា អ្នកកំពុងតែធ្វើដំណើរតាមផ្លូវដើម្បីប្រែក្លាយដូចជាព្រះយេស៊ូវ។ វានឹងជួយដល់ ការចងចាំថាអ្នកមានអារម្មណ៍ដូចជាកូនក្មេងជាយ៉ាងណា ទោះជានៅកណ្ដាលទុក្ខព្រួយ និងឧបសគ្គ។ ចូរគិតអំពីកូនក្មេងទាំងឡាយដែលច្រៀងចំរៀង។ ចូរគិតអំពីគ្រាដែលអ្នកទទួលអារម្មណ៍ ប្រហែលជាក្នុងពេលថ្មីៗនេះ ដូចជាកុមារតូចៗទាំងនោះមាន ច្រៀងបទ "ខ្ញុំខំក្លាយដូចជាព្រះយេស៊ូវ ខ្ញុំធ្វើតាមគំរូនៃទ្រង់"។ អ្នកនឹងចងចាំថា ព្រះយេស៊ូវបានសុំឱ្យពួកសិស្សរបស់ទ្រង់នាំកុមារតូចៗមកឯទ្រង់ ហើយមានបន្ទូលថា "ទុកឱ្យកូនក្មេងមកឯខ្ញុំចុះ... ត្បិតនគរព្រះមានសុទ្ធតែមនុស្សដូចវារាល់គ្នាដែរ"។6 អ្នកមានអារម្មណ៍សេចក្ដីសុខសាន្តនៃកុមារតូចបរិសុទ្ធ នៅពេលអ្នកបានព្យាយាមដូចជាព្រះយេស៊ូវ។

វាអាចនឹងកើតមាន នៅពេលអ្នកបានទទួលបុណ្យជ្រមុជទឹក។ កុមារតូចៗ មិនត្រូវការបុណ្យជ្រមុជទឹក ពីព្រោះពួកគេបរិសុទ្ធ។ ប៉ុន្តែនៅពេលអ្នកទទួលបុណ្យជ្រមុជទឹក អ្នកមានអារម្មណ៍ថាត្រូវបានលាង សំអាតដូចជាកុមារតូចៗ។ នៅពេលទ្រង់បានទទួលបុណ្យជ្រមុជ នោះស្ថានសួគ៌បានបើកឡើង ហើយទ្រង់បានឮសំឡេងរបស់ព្រះវរបិតាសួគ៌ទ្រង់ថា: "នេះជាកូនស្ងួនភ្ងារបស់អញជាទីពេញចិត្តអញណាស់"។7 អ្នកគ្មានឮសំឡេងអ្វីទេ ប៉ុន្តែអ្នកទទួលអារម្មណ៍ការអនុញ្ញាតរបស់ព្រះវរបិតាសួគ៌ ត្បិតបានធ្វើនូវអ្វីដែលព្រះយេស៊ូវបានធ្វើ។

អ្នកបានទទួលអារម្មណ៍នៅក្នុងនេះនៅក្នុងគ្រួសាររបស់អ្នក នៅពេលអ្នកសុំការអភ័យទោសពីប្ដី ឬប្រពន្ធរបស់អ្នក ឬអភ័យទោសដល់កូនចំពោះកំហុស និងការមិនគោរពរបស់គេមួយចំនួន។ ខណៈពេលទាំងនេះ នឹងកើតមានកាន់តែញឹកញាប់ នៅពេលអ្នកព្យាយាមដើម្បីធ្វើនូវរឿងដែលអ្នកដឹងថាព្រះយេស៊ូវនឹងធ្វើ។ ដោយសារតែដង្វាយធួនរបស់ទ្រង់សំរាប់អ្នក នោះការគោរពប្រតិបត្តិដូចជាកូនក្មេងរបស់អ្នក នឹងនាំអារម្មណ៍នៃសេចក្ដីស្រឡាញ់របស់ព្រះអង្គសង្គ្រោះសំរាប់អ្នក និងសេចក្ដីស្រឡាញ់របស់អ្នកចំពោះទ្រង់។ នោះគឺជាអំណោយទានមួយ ដែលត្រូវបានសន្យាចំពោះពួកសិស្សស្មោះត្រង់របស់ទ្រង់។ ហើយអំណោយទាននោះ អាចកើតមានមិនមែនតែចំពោះអ្នកម្នាក់ឯងនោះទេ ប៉ុន្តែចំពោះសមាជិកគ្រួសារជាទីស្រឡាញ់របស់អ្នកផងដែរ។ ការសន្យាត្រូវបានផ្ដល់ឱ្យនៅក្នុងនីហ្វៃទី 3 ថា: "ឯកូនចៅទាំងប៉ុន្មានរបស់អ្នក នឹងធ្វើជាសិស្សរបស់ព្រះអម្ចាស់ ហើយវារាល់គ្នានឹងមានសន្តិសុខជាបរិបូរ"។8

ខ្ញុំសង្ឃឹមថាអ្នកនឹងចេញទៅនៅថ្ងៃនេះ ស្វែងរកឱកាសដើម្បីធ្វើដូចជាទ្រង់បានធ្វើ ហើយស្រឡាញ់ដូចជាទ្រង់ស្រឡាញ់។ ខ្ញុំអាចសន្យាភាពសុខសាន្តនឹងមានដល់អ្នក ដូចជាមានកុមារតូចម្នាក់ ដែលនឹងមកកាន់អ្នកជាញឹកញាប់ ហើយនឹងនៅជាមួយអ្នក។

ការសន្យាគឺជាការពិត ដែលទ្រង់បានសន្យាជាមួយនឹងពួកសិស្សរបស់ទ្រង់ថា ៖ "ខ្ញុំទុកសេចក្ដីសុខនៅនឹងអ្នករាល់គ្នា គឺខ្ញុំឲ្យសេចក្ដីសុខសាន្តរបស់ខ្ញុំដល់អ្នករាល់គ្នា ហើយដែលខ្ញុំឲ្យ នោះមិនមែនដូចជាលោកិយឲ្យទេ" ។9

គ្មានយើងណាម្នាក់ គឺជាមនុស្សដ៏ល្អឥតខ្ចោះនៅឡើយទេ ។ ប៉ុន្តែយើងអាចទទួលការបញ្ជាក់ជាញឹកញាប់ថា យើងកំពុងដើរនៅលើផ្លូវនោះ ។ ទ្រង់ដឹកនាំយើង ហើយទ្រង់បោយព្រះហស្តឲ្យយើងដើរតាមទ្រង់ ។

ខ្ញុំថ្លែងទីបន្ទាល់ថា ផ្លូវដែលមាននូវសេចក្តីជំនឿដល់ព្រះយេស៊ូវគ្រីស្ទ នៅក្នុងពិធីបុណ្យជ្រមុជទឹក ការទទួលព្រះវិញ្ញាណបរិសុទ្ធ និងនៅក្នុងការអត់ធ្មត់ ក្នុងក្តីស្រឡាញ់ ដើម្បីគោរពព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ។ ខ្ញុំថ្លែងទីបន្ទាល់ថា ព្រះវរបិតាមានព្រះជន្មរស់ ហើយស្រឡាញ់យើង ។ ទ្រង់ស្រឡាញ់ព្រះរាជបុត្រាសំណប់របស់ទ្រង់ ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ដែលជា *គំរូដ៏ល្អឥតខ្ចោះរបស់យើង*។ យ៉ូសែប ស្ម៊ីធគឺជាព្យាការីនៃការស្តារឡើងវិញ ។ គាត់បានមើលឃើញព្រះវរបិតា និងព្រះរាជបុត្រា ។ ខ្ញុំដឹងថារឿងនេះពិត ។ មានអំណាចបព្វជិតភាពនៅក្នុងសាសនាចក្រ នៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ដើម្បីផ្តល់ពិធីបរិសុទ្ធទាំងឡាយ ដែលអនុញ្ញាតឲ្យយើងប្រែក្លាយជាមនុស្សកាន់តែប្រសើរឡើង ហើយកាន់តែដូចជាព្រះអង្គសង្គ្រោះ និងព្រះវរបិតាសួគ៌របស់យើង ។ ខ្ញុំបន្សល់ទុកនឹងអ្នករាល់គ្នានូវពរជ័យរបស់ខ្ញុំ ដើម្បីអ្នកអាចទទួលអារម្មណ៍ការអះអាង និងការអនុញ្ញាត ដែលអ្នកបានទទួលអារម្មណ៍ដូចជាកុមារតូចៗ ។ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ។ អាម៉ែន ។

កំណត់ចំណាំ

1. មរ៉ូណៃ 7:48 ។
2. "I'm Trying to Be like Jesus" *Children's Songbook* ទំព័រ 78--79 ។
3. នីហ្វៃទី 3 10:6 ។
4. អ័សុន អែហ្វ វីតនី នៅក្នុង Conference Report ខែ មេសា ឆ្នាំ 1929 ទំព័រ 110 ។
5. ម៉ូសាយ 13:20 ។
6. ម៉ាកុស 10:14 ។
7. ម៉ាថាយ 3:17 ។
8. នីហ្វៃទី 3 22:13 ។
9. យ៉ូហាន 14:27 ។